# ទំនួញទម័ក



នាមជាទម័កអ្នកក្រខ្សត់ ថែមជួបជូរចត់ព្រាត់ស្នេហា
ដឹងខ្លួនតូចទាបក្បៀបវាសនា ហ៊ានត្រឹមប្រាថ្នាផ្កាម្រះព្រៅ។
ធ្លាប់ជួបល្ងាចព្រឹកនឹកអាល័យ បងបរដំរីដឹកភ្ញៀវទៅ
ឯស្ងួនអូនលក់ទឹកអំពៅ មន្តស្នេហ៍ចាក់ជ្រៅនៅដួងចិត្ត។
ពាក្យស្បថសច្ចាមុខអង្គរ ពិរោះបវរល្អពេកពិត
ជាស្ន័គ្រទម័កមួយជីវិត ក្រទ្រព្យមិនគិតសុំចិត្តស្មោះ។
លុះគេអ្នកមានចូលដណ្ដឹង ព្រលឹងព្រមការឥតស្រណោះ
ទឹកភ្នែកទម័កធ្លាក់ស្មើរខ្សោះ ស្នេហ៍ស្មោះមិនឈ្នះព្រះប្រាក់អើ!
ទុក្ខក្រំឱរាផ្សាចាប់ចុក ខ្ញុំឈរសំកុកមុខដំរី
ស្រាប់មានគេហៅហើយគេស្ដី ដឹកគូមេត្រីគេលំហែ។
តើខ្ញុំគួរសើចឬគួរយំ យល់សង្សារខ្ញុំប្រពន្ធគេ
ស្វាមីកៀកកងផ្ដោះផ្គងស្នេហ៍ ឯខ្ញុំគ្រាន់តែជាទម័ក៕

**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**